# សំណួរ-ចម្លើយ ប្រវត្តិវិទ្យា សំខាន់ៗ

អ៊ិន សុវណ្ណារ័ត្ន

**១.តើស្តេចខ្មែរ ដែលសោយរាជ្យ នៅសម័យអាណានិគមបារាំងមានអង្គណាខ្លះ?**

**ស្តេចខ្មែរ ដែលសោយរាជ្យ** នៅសម័យអាណានិគមបារាំងមាន ៤អង្គគឺៈ

- ព្រះបាទ **នរោត្តម** (១៨៦០-១៩០៤)
- ព្រះបាទ **ស៊ីសុវត្ថិ** (១៩០៤-១៩២៧)
- ព្រះបាទ **ស៊ីសុវត្ថិ មុនីវង្ស** (១៩២៧-១៩៤១)
- ព្រះបាទ **នរោត្តម សីហនុ** (១៩៤១-១៩៥៥)

**២.តើកត្តាអ្វីខ្លះ ដែលជំរុញឲ្យបារាំងប្រគល់ឯករាជ្យជូនប្រជាជាតិខ្មែរ?**

**កត្តាដែលជំរុញឲ្យបារាំងប្រគល់ឯករាជ្យជូនប្រជាជាតិខ្មែរ** រួមមានៈ

- ការលេចឡើងនូវចលនាជាតិនិយម និងចលនាខ្មែរឥស្សរៈ
- ព្រះរាជបូជនីយកិច្ចរបស់ព្រះបាទ នរោត្តម សីហនុ
- ប្រជាជនខ្មែរ ងើបបះបោរទាមទារឯករាជ្យ
- បារាំងចុះខ្សោយ ជួបវិបត្តិនានា និងឥទ្ធិពល នៃសង្គ្រាមត្រជាក់។

**៣.តើសន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ គឺជាអ្វី? ស្តីពីបញ្ហាអ្វី?**

**សន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤** គឺ

- ជាសន្និសីទថ្នាក់រដ្ឋមន្ត្រីការបរទេស ដែលមានប្រទេសចំនួន ១៩ចូលរួម
- សន្និសីទស្តីពី បញ្ហាឥណ្ឌូចិន។

**៤.តើសេចក្តីសម្រេច នៃសន្និសីទទីក្រុងហ្សឺណែវទាក់ទងនឹងកម្ពុជា មានអ្វីខ្លះ?**

**សេចក្តីសម្រេច នៃសន្និសីទទីក្រុងហ្សឺណែវ** ទាក់ទងនឹងកម្ពុជា រួមមានៈ

- កម្ពុជា ជារដ្ឋអធិបតេយ្យភាពតែមួយគត់ ដែលពុំអាចបំបែកបាន
- បារាំង និងសហគមន៍អន្តរជាតិទទួលស្គាល់ និងគោរពឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី នៃកម្ពុជា
- កម្ពុជា ត្រូវអនុវត្តន៍នយោបាយអព្យាក្រឹត តាមការស្នើសុំរបស់ ចិន និងសូវៀត
- ការបញ្ឈប់សកម្មភាពយោធានានា នៅកម្ពុជា ត្រឹមថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៥៤
- ការដកទ័ពបរទេសទាំងអស់ចេញពីកម្ពុជា ក្នុងអំឡុងពេល ៩០ថ្ងៃ
- ការរំសាយកងកម្លាំងខ្មែរឥស្សរៈ ក្នុងអំឡុងពេល ៣០ថ្ងៃ។

**៥.តើសមាជជាតិ ផ្តល់លទ្ធផលអ្វីខ្លះ?**

អ៊ិន សុវណ្ណារ័ត្ន

**លទ្ធផល នៃសមាជជាតិ** រួមមានៈ

- ការប្រឆាំងនឹងអំពើពុករលួយ
- ការកំណត់យកភាសាខ្មែរ ជាភាសាផ្លូវការ
- សភាតំណាងរាស្ត្រ មានសិទ្ធិចូលរួមក្នុងការកែលម្អសកម្មភាពរដ្ឋបាល និងទាមទារឲ្យដាក់ទណ្ឌកម្ម ចំពោះមន្ត្រីអសកម្ម
- ផ្តល់សិទ្ធិឲ្យស្ត្រីចូលរួមបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត (៦ មករា ១៩៥៨)

**៦.តើឥស្សរជននយោបាយសំខាន់ៗ នៃរដ្ឋាភិបាលស្រោចស្រង់ជាតិ ក្នុងរបបសង្គមរាស្ត្រនិយម មាននរណាខ្លះ?** **ឥស្សរជននយោបាយសំខាន់ៗ នៃរដ្ឋាភិបាលស្រោចស្រង់ជាតិ ក្នុងរបបសង្គមរាស្ត្រនិយម** រួមមាន លោក លន់ នល់ ; ស៊ីសុវត្ថិ សិរីមតៈ ; ចេង ហេង ; អ៊ិន តាំ និងឡុង បូរ៉េត។

**៧.តើខ្មែរក្រហម បណ្តេញប្រជាជន ចេញពីទីក្រុងភ្នំពេញ ក្រោមលេសប៉ុន្មាន?**

***<u>ខ្មែរក្រហម បានបណ្តេញប្រជាជន ចេញពីទីក្រុងភ្នំពេញ</u>*** ក្រោមលេស ៣យ៉ាងគឺ

- អង្គការត្រូវបោសសម្អាតខ្មាំង
- ខ្លាចអាមេរិកាំងមកទម្លាក់គ្រាប់បែក
- ខ្វះមធ្យោបាយដឹកស្បៀងឲ្យប្រជាជន នៅទីក្រុងភ្នំពេញ។

**៨.ហេតុអ្វីបានជា ខ្មែរក្រហម អនុវត្តន៍ផែនការ ៤ឆ្នាំ?**

**<u>ការអនុវត្តផែនការ ៤ឆ្នាំ របស់ខ្មែរក្រហម</u>** ពីព្រោះពួកគេសង្ឃឹមថា នឹងធ្វើឲ្យប្រទេសកម្ពុជារីកចម្រើន ក្លាយជាប្រទេសកសិកម្មទំនើប ក្នុងរយៈពេល ១០ ទៅ ១៥ឆ្នាំ និងក្លាយជាប្រទេសឧស្សាហកម្ម ក្នុងរយៈពេល ១៥ ទៅ ២០ឆ្នាំ។

**៩.តើផែនការ ៤ឆ្នាំ មានគោលការណ៍ដូចម្តេច?**

**ផែនការ ៤ឆ្នាំ** មានគោលការណ៍តម្រូវឲ្យ

- ប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់ ដាក់ជាសម្បត្តិរួម
- បែងចែកកម្លាំងពលកម្មទៅតាមក្រុមរៀងៗខ្លួនដូចជា បុរស ស្ត្រី និងកុមារ
- ពង្រីកផលិតផលស្រូវឲ្យបានជាមធ្យម ៣តោន ក្នុង ១ហិចតា
- ដាំដំណាំផ្សេងៗ ចិញ្ចឹមសត្វ នេសាទ និងអនុផលព្រៃឈើ សម្រាប់នាំចេញ។

**១០.តើគោលការណ៍ ៨ប្រការ របស់ខ្មែរក្រហមមានអ្វីខ្លះ?**

**គោលការណ៍ ៨ប្រការ របស់ខ្មែរក្រហម** រួមមានៈ

- ជម្លៀសប្រជាជនឲ្យចេញពីទីក្រុងភ្នំពេញទាំងអស់
- លុបបំបាត់ទីផ្សារ
- លុបបំបាត់ការប្រើប្រាស់ និងចរាចរណ៍រូបិយប័ណ្ណ
- ផ្សឹកលោកសង្ឃ ក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ ហើយឲ្យទៅធ្វើស្រែចម្ការ នៅតំបន់មូលដ្ឋានជនបទ
- ប្រហារជីវិតមេដឹកនាំ របស់របប លន់ នល់
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស
- បណ្តេញជនជាតិភាគតិចវៀតណាម ឲ្យចេញទាំងអស់
- បញ្ជូនទ័ពទៅតាមព្រំដែន ជាពិសេសព្រំប្រទល់វៀតណាម។

**១១.តើអ្នកណាខ្លះ ដែលត្រូវចោទថា ជាខ្មាំងរបស់អង្គការ?**

**អ្នកដែលត្រូវចោទថា ជាខ្មាំងរបស់អង្គការ** រួមមានៈ

- មន្ត្រីរដ្ឋការរបស់របប លន់ នល់ និងប្រជាជនមានកំហុស
- ភ្នាក់ងារសម្ងាត់បរទេស
- សូវៀត អាមេរិក វៀតណាម និងថៃ
- ប្រជាជនថ្មី និងជនជាតិភាគតិច។

**១២.តើរណសិរ្សសាមគ្គីសង្គ្រោះជាតិ បង្កើតឡើងក្នុងគោលបំណងអ្វី?**

**រណសិរ្សសាមគ្គីសង្គ្រោះជាតិ** បង្កើតឡើងក្នុងគោលបំណងដូចតទៅៈ

- ផ្តួលរំលំរបបប្រល័យពូជសាសន៍ខ្មែរក្រហម
- រំដោះប្រទេសពីរបប ប៉ុល ពត
- រំដោះប្រជាជនពីការសម្លាប់រង្គាល
- រៀបចំស្តារ និងកសាងប្រទេសឡើងវិញ។

**១៣.តើព្រឹត្តិការណ៍អន្តរជាតិណាខ្លះ ដែលអំណោយផល ដល់ការចរចារកសន្តិភាព នៅកម្ពុជា?**

***<u>ព្រឹត្តិការណ៍ ដែលអំណោយផលដល់ការចរចារកសន្តិភាព</u>*** នៅកម្ពុជាគឺៈ

- កំណែទម្រង់ប៉េរ៉េស្ត្រយកា (១៩៨៥)
- កំណែទម្រង់ដួយម៉ឺយ (១៩៨៦)
- ដំណើរទស្សនកិច្ចរបស់លោក អាលីអាឡាតាស់ នៅវៀតណាម (១៩៨៧)
- ជំនួបកំពូលរវាងសហរដ្ឋអាមេរិក និងសហភាពសូវៀត (១៩៨៧)
- សូវៀតដកទ័ពចេញពីប្រទេសអាហ្វហ្គានីស្ថាន និងដកក្បាលកាំជ្រួចចេញពីតំបន់ស៊ីបេរី (១៩៨៩)។

**១៤.តើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មានខ្លឹមសារសំខាន់ដូចម្តេចខ្លះ?**

**កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស** មានខ្លឹមសារសំខាន់ដូចតទៅៈ

- កំណត់គោលការណ៍ថ្មី នៃរដ្ឋធម្មនុញ្ញ
- ការដកទ័ពបរទេសចេញពីកម្ពុជា និងការកាត់រំសាយកងទ័ព
- ការឈប់បាញ់គ្នា រវាងភាគីជម្លោះទាំង៤ និងការធ្វើមាតុភូមិនិវត្តន៍
- ការកំណត់អាណត្តិអ៊ុនតាក់ និងការបោះឆ្នោត។

**យុវជនដែលទំពើង គឺជាទ្រព្យសម្បត្តិរបស់សង្គម**